**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

## ករណីកូដកម្ម បាតុកម្មនៅក្រុមហ៊ុន ដាប់ប៊ែលយូ អ៊ែនដ៍ឌី (W&D)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមស្វាគមន៍ចំពោះបងប្អូនកម្មករនិយោជិត និងអង្គការសហជីព ដែលបានគាំទ្រអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ពាក់ព័ន្ធនឹងការទូទាត់ប្រាក់រំលឹកអតីតភាពការងារ ដោយអនុវត្តទាំងស្រុងតាមច្បាប់ និងខ្លឹមសារប្រកាសលេខ៤៤៣ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ដោយបងប្អូននឹងមិនទាមទារតវ៉ាលើករណីនេះទៀតឡើយ។

ជាមួយគ្នានេះ ក្រសួងក៏សូមអំពាវនាវដល់កម្មករនិយោជិត និងអង្គការសហជីព បន្តសកម្មភាពរបស់ខ្លួនក្នុងស្មារតីស្ថាបនានិងគោរពតាមច្បាប់ និងនីតិវិធីជាធរមានក្នុងការធ្វើសកម្មភាពនានា ហើយសូមជៀសវាងការធ្វើសកម្មភាពណាមួយដែលធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ។

ចំពោះករណីកូដកម្ម បាតុកម្មនៅក្រុមហ៊ុន ដាប់ប៊ែលយូ អ៊ែនដ៍ឌី (W&D) ក្រសួងនឹងបន្តសម្របសម្រួលដោះស្រាយដោយឈរលើគោលការណ៍ទាំង២ ចំណុចខាងលើ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១៤កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៩

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩